**Declassified to Public**
**06 September 2012**



**ខៀវ សំផនធ្វើជាអធិបតីសម័យប្រជុំសមាជរបស់ រណៈសិរ្សរួបរួមជាតិនៃកម្ពុជា៖ សេចក្តីថ្លែងការណ៍ដែលត្រូវបានផ្សព្វផ្សាយ**

**វិទ្យុផ្សាយសម្លេងរណៈសិរ្សរួបរួមជាតិនៃកម្ពុជា [ផ្សាយដោយលួចលាក់] ជាភាសាខ្មែរទៅកាន់ប្រទេសកម្ពុជា** 1130 GMT **ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥** BK

**["អត្ថបទ" សេចក្តីថ្លែងការណ៍សារព័ត៌មានចុះថ្ងៃទី២៦ ខែកុម្ភៈស្តីអំពីសម័យប្រជុំលើកទី២ ពីថ្ងៃទី២៤-២៥ ខែកុម្ភៈ របស់សមាជជាតិដែលបានប្រារព្វធ្វើដោយតំណាងនៃរណៈសិរ្សរួបរួមជាតិនៃកម្ពុជា និងអង្គការមហាជនក៏ដូចជាតំណាង នៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិ និងប្រជាជនកម្ពុជាទាំង ៣ប្រភេទ៖ អានដោយអ្នកធ្វើអត្ថាធិប្បាយ]**

[អត្ថបទ] ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ សមាជជាតិដ៏មហាអស្ចារ្យបានប្រារព្ធសម័យប្រជុំលើកទី២ របស់ខ្លួននៅក្នុងតំបន់រំដោះក្រោមអធិបតីភាពរបស់លោក ខៀវ សំផន ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជារដ្ឋមន្ត្រីការពារជាតិ និងនាយសេនាធិការនៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិ និងប្រជាជនកម្ពុជា។ សមាជនេះត្រូវបានចូលរួមដោយរដ្ឋមន្ត្រី និងអនុរដ្ឋមន្ត្រី និងតំណាង ២៧៣រូប នៃថ្នាក់លើទាំងអស់នៃរណៈសិរ្សរួបរួមជាតិកម្ពុជា និងអង្គការមហាជនគ្រប់ប្រភេទ រួមមានសមាគមនារីប្រជាធិបតេយ្យ សមាគមយុវជនប្រជាធិតេយ្យ សមាគមកសិករ សហជីពពាណិជ្ជកម្ម សមាគមព្រះសង្ឃស្នេហាជាតិ សមាគមបញ្ញាវ័ន្តស្នេហាជាតិ សមាគមអ្នកនិពន្ធ និងអ្នកនិពន្ធកំណាព្យស្នេហាជាតិ និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិ និងប្រជាជនកម្ពុជាទាំង ៣ប្រភេទ មកពីភូមិភាគ តំបន់ និងផ្នែកទាំងអស់ទូទាំងប្រទេសកម្ពុជា។

សម័យប្រជុំសមាជជាតិដ៏មហាអស្ចារ្យលើកទី២ នេះត្រូវបានប្រារព្ធធ្វើឡើងនៅចំពេលមួយដែលលក្ខខណ្ឌយោធា នយោបាយ និងសេដ្ឋកិច្ចបានផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងលក្ខណៈមួយដ៏អំណោយផលខ្លាំងមែនទែនចំពោះការតស៊ូរំដោះជាតិរបស់ប្រជាជន និងប្រជាជាតិកម្ពុជា។ បច្ចុប្បន្ននេះ យើងកំពុងធ្វើការវាយប្រហារពីគ្រប់ទិស។ ខ្មាំងកំពុងរកកលដួលរលំក្នុងគ្រប់វិស័យ។ ទីក្រុងភ្នំពេញកំពុងត្រូវបានហ៊ុំព័ទ្ធទាំងស្រុង ហើយខ្មាំងកំពុងត្រដរខ្យល់ទាំងផ្នែកយោធា នយោបាយ និងសេដ្ឋកិច្ច និងកង្វះគ្រាប់រំសេវ។

Original EN: 00166772-00166775

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 27 / 11 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 27 / 11 / 2008
ម៉ោង (Time/Heure): 14 : 20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

នៅក្នុងកាលៈទេសៈដ៏អំណោយផលដ៏ខ្លាំងក្លាទាំងនេះ សមាជជាតិដ៏អស្ចារ្យបានធ្វើការពិភាក្សាយ៉ាងខ្លាំងក្លា និងយ៉ាងជ្រាលជ្រៅរយៈពេល២ថ្ងៃ ហើយបានចេញផ្សាយនូវសេចក្ដីប្រកាសជាច្រើនអំពីបញ្ហាដ៏មានសារៈសំខាន់ផ្សេងៗរួមទាំងបញ្ហាដូចខាងក្រោម៖

១. ទាក់ទងនឹងពួកក្បត់ទាំង ៧នាក់នៅក្នុងទីក្រុងភ្នំពេញ សមាជជាតិបានសម្រេចដូចតទៅ៖ ពួកក្បត់ជាតិ លន់ ណុល សីរិមៈតៈ សឺង ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និង Sosthene Fernandez គឺជាប្រមុខពួកក្បត់ និងជាប្រធានក្រុមធ្វើរដ្ឋប្រហារប្រឆាំងជាតិដ៏ទុយ៌សដែលបានផ្ដួលរំលំឯករាជ្យ សន្តិភាព និងអព្យាក្រិតភាពរបស់កម្ពុជា។ ពួកវាគឺជាអ្នកដែលបានអន្ទងពួកចក្រពត្តិអាមេរិកឱ្យចូលលុកលុយ និងរុញច្រានប្រទេសកម្ពុជាឱ្យធ្លាក់ក្នុងអណ្ដាតភ្លើង និងនាំមកនូវការបំផ្លិចបំផ្លាញដែលមិនដែលធ្លាប់មាន និងដែលមិនអាចពណ៌នាបាន ព្រមទាំងការឈឺចាប់ចំពោះប្រទេសកម្ពុជា និងសេចក្ដីមរណៈចំពោះព្រះសង្ឃ និងប្រជាជនជាច្រើននាក់រួមទាំងបុរស ស្ត្រី និងកុមារ។ ក្នុងនាម រណៈសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា សមាជជាតិបានប្រកាស ថាវាជាការចាំបាច់ជាដាច់ខាតត្រូវសម្លាប់ជនក្បត់ជាតិទាំង ៧ នាក់នេះចំពោះអំពើក្បត់ជាតិរបស់ពួកវាដែលប្រឆាំងនឹងប្រជាជាតិ និងអំពើហ្វាស៊ីស ពុករលួយ ឧក្រិដ្ឋកម្ម ដែលមិនដែលធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា។ ចំពោះមន្ត្រីរាជការថ្នាក់ទាប និងខ្ពស់ ដទៃទៀតនៃក្រសួងផ្សេងៗ នាយទាហាន នាយនគរបាល នគរបាលគ្រប់ប្រភេទ សមាជិកនៃផ្នែក ស្វ័យការពារ ផ្នែកប្រដាប់អាវុធដទៃទៀត អ្នកនយោបាយ អ្នកមុខអ្នកការធំៗ និងសមាជិកគ្រប់ប្រភេទនៅក្នុងគ្រប់អង្គការនៃរបបរបស់ពួកក្បត់ និងតាងនាមឱ្យប្រជាជាតិ និងប្រជាជនកម្ពុជា រណៈសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា សមាជជាតិសូមប្រកាសថា អ្នកទាំងអស់នេះមានសិទ្ធិពេញលេញដើម្បីចូលរួមជាមួយរណៈសិរ្សរួបរួមជាតិកម្ពុជា ប្រជាជាតិ និងប្រជាជនកម្ពុជា និងអំពាវនាវឱ្យអ្នកទាំងអស់នេះបោះបង់ចោលការងាររបស់ពួកគេក្នុងការបម្រើជនក្បត់ទាំង ៧នាក់ និងបញ្ឈប់សហប្រតិបត្តិការជាមួយពួកក្បត់ទាំងនេះ។

ប្រជាជាតិ និងប្រជាជនកម្ពុជា រណៈសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាសូមស្វាគមន៍ និងផ្ដល់រង្វាន់ដ៏សមគួរដល់នាយទាហាន កងទ័ព កងឈ្លប នគរបាល អ្នកមុខអ្នកការ អ្នកនយោបាយ និងអ្នកមានបណ្ដាសក្តិខ្ពង់ខ្ពស់ដែលរស់នៅក្នុងតំបន់កាន់កាប់បណ្ដោះអាសន្នរបស់ខ្មាំងដែលហានប្រឆាំងនឹងពួកក្បត់ ប្រយុទ្ធតស៊ូនឹងពួកវា និងបង្វែរចុងកាណុងដាក់ពួកវា។

ចំពោះហេតុផលនេះ តាងនាមឲ្យប្រជាជាតិ និងប្រជាជនកម្ពុជា រណៈសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះ ជាតិកម្ពុជា សមាជជាតិសូមអំពាវនាវដល់ នាយទាហាន កងទ័ព នាយនគរបាល នគរបាល កងឈ្លប អ្នកមុខអ្នកការ អ្នកនយោបាយ និងជនគ្រប់រូបដែលរស់នៅក្នុងតំបន់កាន់កាប់បណ្តោះអាសន្នរបស់ខ្មាំងសូមបោះបង់ចោលពួកក្បត់ទាំង ៧នាក់ដែលកំពុងប្រឈមមុខនឹងការភ័យតក់ស្លុត និងរួមចំណែកដល់សកម្មភាពរបស់ប្រជាជននៅក្នុងទីក្រុងភ្នំពេញ និងតំបន់ដទៃទៀតដែលស្ថិតនៅក្រោមការកាន់កាប់បណ្តោះអាសន្នរបស់ខ្មាំងធ្វើការតស៊ូប្រឆាំងនឹងពួកក្បត់ដោយរិះរកគ្រប់មធ្យោបាយដើម្បីបំផ្លាញក្បាលម៉ាស៊ីនរដ្ឋបាលក្បត់របស់ពួកវា ទីតាំងយោធា និងស្ថានីយ៍នគរបាល ឃ្លាំងគ្រាប់រំសេវ និងឃ្លាំងស្បៀងអាហារ និងប្រេងឥន្ធនៈ ព្រមទាំងបង្វែរចុងកាណុងរបស់អ្នកប្រឆាំងនឹងពួកវា ដើម្បីរួមចំណែកដល់ការរំដោះជាតិ និងប្រជាជន។

២. ចំពោះចក្រពត្តិអាមេរិកដែលបានមកធ្វើអន្តរាគមន៍ និងធ្វើសង្គ្រាមប្រឆាំងនឹងប្រទេសកម្ពុជា និងបន្តឲ្យខ្មែរនិងខ្មែរធ្វើសង្គ្រាមបង្ហូរឈាមគ្នា (pursue their Khmerization of the war) ដែលបណ្តាលឲ្យមានការស្លាប់រាប់មិនអស់ ក៏ដូចជាការបំផ្លិចបំផ្លាញ និងបង្កគ្រោះថ្នាក់គ្មានព្រំដែន តាងនាមឲ្យប្រជាជាតិ និងប្រជាជនកម្ពុជា រណៈសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា សមាជជាតិជាថ្មីម្តងទៀតសូមប្រកាសថា ប្រជាជាតិ និងប្រជាជនកម្ពុជាកំពុងធ្វើការតស៊ូដែលដឹកនាំដោយ រណៈសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាធ្វើឲ្យចក្រពត្តិអាមេរិកបញ្ឈប់នូវសកម្មភាពអន្តរាគមន៍ និងឈ្លានពានដោយផ្ទាល់ និងមិនផ្ទាល់របស់ពួកវាប្រឆាំងនឹងប្រទេសកម្ពុជា និងធ្វើការដកចេញនូវទីប្រឹក្សាយោធា និងទីប្រឹក្សាសន្តិភាវកម្មទាំងអស់របស់ពួកវា និងទីភ្នាក់ងារផ្តល់ជំនួយដែលទទួលស្គាល់ដោយបនក្បត់ជាតិទីក្រុងភ្នំពេញ។ ប្រជាជាតិ និងប្រជាជនកម្ពុជា រណៈសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា កំពុងតស៊ូដោយគ្មានគោលបំណងធ្វើអន្តរាគមន៍ ឬធ្វើការឈ្លានពានប្រឆាំងនឹងសហរដ្ឋអាមេរិក ឬប្រជាជនរបស់វា ឬប្រឆាំងនឹងប្រទេស និងប្រជាជនជិតឆ្ងាយ។ យើងកំពុងធ្វើការតស៊ូនេះគឺដើម្បីទាមទារសិទ្ធិមានសេរីភាព និងថែរក្សាឯករាជ្យជាតិ និងកិត្តិយសជាតិរបស់យើង។

៣. តាងនាមឲ្យប្រជាជាតិ និងប្រជាជនកម្ពុជា រណៈសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា សមាជជាតិសូមគូសបញ្ជាក់យ៉ាងឧឡារិកនូវគោលនយោបាយទាំងក្នុង និងក្រៅរបស់យើងដូចខាងក្រោម៖

នៅខាងក្នុងប្រទេស តាងនាមឲ្យប្រជាជាតិ និងប្រជាជនកម្ពុជា រណៈសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សូមធានាខុសត្រូវចំពោះជោគវាសនារបស់ប្រជាជាតិ និងគោរព ចំពោះជំហរនៃឯកភាពជាតិ និងប្រជាជនដ៏ធំមហិមាដោយមិនគិតអំពីវណ្ណៈសង្គម និន្នាការនយោបាយ ជំនឿសាសនា ឬអតីតកាល [នយោបាយ] របស់ពួកគេ លើកលែងតែពួកក្បត់ជាតិ លន់ ណុល សីរិមៈតៈ សឺង ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និង Sosthene Fernandez ដើម្បីកសាង ប្រទេសដ៏សម្បូររុងរឿងមួយ ដើម្បីប្រជាជនមានម្ហូបអាហារ សម្លៀកបំពាក់ និងផ្ទះសម្បែងគ្រប់គ្រាន់ និងទទួលបានការថែទាំបែបវេជ្ជសាស្ត្រ និងការអប់រំគ្រប់គ្រាន់។

នៅក្នុងគោលនយោបាយការបរទេសរបស់យើង រណៈសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រកាន់ខ្ជាប់នូវជំហរដោយឥតងាករេចំពោះឯករាជ្យភាព និងការមិនចូលបក្សសម្ព័ន្ធដោយមិនអនុញ្ញាតឲ្យពួកបរទេសណាម្នាក់បង្កើតមូលដ្ឋានយោធាដើម្បីឈ្លានពានលើទឹកដីនៃប្រទេសកម្ពុជា និងគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ ៥ចំណុច៖ ការបង្កើតឲ្យមានសន្តិភាពក្នុងតំបន់ (peaceful coexistence) ការមានទំនាក់ទំនងល្អជាមួយប្រទេសជិតឆ្ងាយដោយមិនគិតពីប្រព័ន្ធនយោបាយ ឬសង្គមរបស់ប្រទេសទាំងនោះឡើយប្រសិនបើប្រទេសទាំងនោះគោរពគោលការណ៍ស្មើភាពគ្នា ការគោរពគ្នាទៅវិញទៅមកដើម្បីផលប្រយោជន៍ទៅវិញទៅមក ការមិនឈ្លានពានគ្នា និងការមិនលូកដៃចូលកិច្ចការផ្ទៃក្នុងរវាងប្រទេស និងប្រទេស។ ប្រជាជាតិ និងប្រជាជនកម្ពុជានឹងទទួលយកនូវជំនួយពីប្រទេសទាំងអស់ដែលជួយយើងដោយមិនមានលក្ខខណ្ឌ។

៤. តាងនាមរណៈសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សមាជជាតិសូមអំពាវនាវដល់ប្រជាពលរដ្ឋរស់នៅក្នុងទីក្រុងភ្នំពេញ និងទីរួមខេត្តមួយចំនួននៅក្រោមការកាន់កាប់បណ្តោះអាសន្នរបស់ខ្មាំង រួមមានព្រះសង្ឃ គ្រហស្ថ កម្មករ ពលករ សិស្ស និស្សិត គ្រូបង្រៀន និងសាស្ត្រាចារ្យឲ្យងើបឈរឡើង និងរួបរួមគ្នានៅក្នុងការតស៊ូក្នុងទម្រង់គ្រប់បែបយ៉ាងប្រឆាំងនឹងបនក្បត់ដើម្បីផ្តួលរំលំពួកវា។

នៅក្រោមការវាយប្រហារដូចព្យុះ និងដ៏ខ្លាំងក្លារបស់កងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជាពីគ្រប់ទិសទាំងអស់ បនក្បត់ជាតិទីក្រុងភ្នំពេញបច្ចុប្បន្ននេះកំពុងភាន់ភាំង ភ័យស្លន់ស្លោនិងជិតដួលរលំទាំងស្រុង។ យើងសុំឲ្យអ្នកក្រោកឈរឡើង រួបរួមគ្នា និងប្រយុទ្ធជាមួយពួកក្បត់ជាតិមកពីខាងក្នុងដោយប្រើគ្រប់ទម្រង់ប្រឌិតញាណទាំងអស់មានដូចជា ការរៀបចំអង្គប្រជុំ ធ្វើបាតុកម្ម និងកូដកម្ម ការប្រឆាំងនឹងសេចក្តីព្រាងផ្សេងៗ ការតវ៉ាប្រឆាំងនឹងភាពអត់ឃ្លាន ការសម្រុកចូលទៅក្នុងតូបលក់

អង្ករ និងឃ្លាំងផ្គត់ផ្គង់ ការរឹបអូសអាវុធពីខ្មាំង និងការវាយប្រហារទីតាំងរដ្ឋបាលខេត្ត សាលាក្រុង ស្ថានីយ៍វិទ្យុ ប៉ុស្តិ៍តម្រួត ស្ថានីយ៍ប៉េអឹម ជម្រុំយោធា ទីបញ្ជាការយោធា និងហេដ្ឋារចនាសម្ព័ន្ធនយោបាយ យោធា និងសេដ្ឋកិច្ចរបស់ខ្មាំង។ ប្រសិនបើចាំបាច់ សូមអ្នកឆ្លងចូលមកតំបន់រំដោះ។ រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងថ្នាក់លើទាំងអស់នៃអង្គការរណសិរ្សនឹងទទួលស្វាគមន៍យ៉ាងកក់ក្តៅចំពោះអ្នក ហើយនឹងជួយអ្នកឲ្យអស់ពីចិត្តពីថ្លើមទាំងស្មារតី និងសម្ភារៈនៅក្នុងជីវភាពរស់នៅថ្មីរបស់អ្នកនៅក្នុងតំបន់រំដោះ។

៥. នៅពេលដែលរបបរបស់ពួកក្បត់ជាតិភ្នំពេញកំពុងរងទុក្ខលំបាក និងដួលរលំ ជាពិសេសនៅពេលដែលក្រដាសប្រាក់រៀលរបស់បនក្បត់ជាតិបានដួលរលំទាំងស្រុងទាំងនៅក្នុង និងក្រៅប្រទេស សមាជជាតិបានសម្រេចថា មកដល់ពេលនេះ ក្រដាសប្រាក់រៀលរបស់បនក្បត់ជាតិភ្នំពេញនឹងលែងប្រើប្រាស់ ហើយនឹងជំនួសដោយក្រដាសប្រាក់ថ្មីរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងធនាគារដ៏មានសមត្ថភាពរបស់ខ្លួននឹងចាត់វិធានការជាក់ស្តែងជាជំហានៗដើម្បីដាក់ឲ្យចរាចរក្រដាសប្រាក់ថ្មីនេះ។

នៅក្នុងអតីតកាល នៅក្នុងតំបន់រំដោះ ការរីកចម្រើនផ្នែកសេដ្ឋកិច្ច-ហិរញ្ញវត្ថុរបស់យើង ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន នឹងល្បឿននៃការរំដោះជាតិរបស់យើងបានដំណើរការដោយមិនមានឧបសគ្គ ពីព្រោះគោលនយោបាយសេដ្ឋកិច្ច-ហិរញ្ញវត្ថុរបស់យើងបានផ្អែកជាសំខាន់លើប្រព័ន្ធដោះដូរគ្នា (barter system)។ ជាបន្តបន្ទាប់ យើងបានឈប់ប្រើប្រាស់ក្រដាសប្រាក់របស់ខ្មាំង។ ក្នុងឆ្នាំ ១៩៧៣ យើងបានប្រើក្រដាសប្រាក់របស់ខ្មាំងចំនួន ១៥ភាគរយនៃកិច្ចការជំនួញទាំងអស់របស់យើងនៅក្នុងតំបន់រំដោះ ចំនួន ៥ភាគរយនៅក្នុងឆ្នាំ ១៩៧៤ និងចំនួន ០.៥ភាគរយក្នុងឆ្នាំ ១៩៧៥។ ចាប់ពីពាក់កណ្តាលខែកុម្ភៈ យើងបានឈប់ប្រើប្រាស់ក្រដាសប្រាក់របស់ខ្មាំងទាំងស្រុង។ នៅពេលអនាគត យើងនឹងនៅតែបន្តធ្វើការដោះដូរទំនិញ ក្នុងអំឡុងពេលដែលកំពុងដាក់ឲ្យចរាចរជាបន្តបន្ទាប់នូវក្រដាសប្រាក់របស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ដូច្នេះ ទិដ្ឋភាពសេដ្ឋកិច្ច-ហិរញ្ញវត្ថុនៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនយើង និងសង្គ្រាមរំដោះជាតិនឹងកាន់តែងាយស្រួល។

ទាក់ទងនឹងប្រជាជនគ្រប់សង្គមជាន់ថ្នាក់ មានបុគ្គលិករាជការជាន់ខ្ពស់គ្រប់ប្រភេទ និងថ្នាក់លើ ទាំងអស់នៃកងទ័ព ទាហ៊ាន និងនគរបាលដែលបានបោះបង់ចោលខ្មាំងមកចូលរួមនៅក្នុងតំបន់រំដោះ ម្តងម្នាក់ៗ។ គោលនយោបាយរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងអង្គការគ្រប់ជាន់

ថ្នាក់របស់ ថ្នាក់លើទាំងអស់នៃអង្គការរបស់រណៈសិរ្សរួបរួមជាតិកម្ពុជាគឺត្រូវជួយពួកគេឲ្យមានជីវភាពរស់នៅ ដោយផ្តល់ដល់ពួកគេនូវការផ្គត់ផ្គង់ និងមធ្យោបាយផលិតគ្រប់គ្រាន់ ដែលអាចជួយពួកគេឲ្យរស់ដោយសប្បាយចិត្តដោយមិនប្រើប្រាស់ក្រដាសប្រាក់របស់ខ្មាំង។ ដូច្នេះ សូមបងប្អូនជនរួមជាតិមកពីគ្រប់ សង្គមជាន់ថ្នាក់ដែលកំពុងរស់នៅក្នុងទីក្រុងភ្នំពេញ និងទីរួមខេត្តផ្សេងៗនៅក្រោមការកាន់កាប់បណ្តោះ អាសន្នរបស់ខ្មាំង បងៗមន្ត្រីរាជការ បងៗកងទ័ព និងនាយទាហ៊ានថ្នាក់លើទាំងអស់ ព្រមទាំងបងៗ នាយនគរបាល និងនគរបាលថ្នាក់លើទាំងអស់ដែលមានបំណងផ្តាច់ខ្លួនពីពួកក្បត់ជាតិមកចូលរួមនៅ ក្នុងតំបន់រំដោះមិនត្រូវព្រួយបារម្ភអំពីមធ្យោបាយរស់នៅក្នុងតំបន់រំដោះឡើយ។ យើងសូមអញ្ជើញអ្នកមកតំបន់រំដោះ ហើយយើងសូមធានាថា អ្នកនឹងមានមធ្យោបាយគ្រប់គ្រាន់សម្រាប់ការរស់នៅ និងធ្វើការនៅទីនោះ។

៦. តាំងនាមឲ្យប្រជាជាតិ និងប្រជាជនកម្ពុជា រណៈសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា សមាជជាតិសូមអំពាវនាវម្តងទៀតដល់ស្ថានទូតបរទេសទាំងអស់ និងអង្គការបរទេសទាំងអស់ដែលត្រូវបានទទួលស្គាល់ដោយរបបរបស់បនក្បត់ជាតិឲ្យធ្វើការជម្លៀសជាបន្ទាន់នូវបុគ្គលិក និងកូនចៅនៅក្នុងបន្ទុករបស់ពួកគេពីទីក្រុងភ្នំពេញ និងតំបន់ផ្សេងៗនៅក្រោមការកាន់កាប់បណ្តោះអាសន្នរបស់ខ្មាំងដើម្បីចៀសវាងការខូចខាតផ្សេងៗ។ បើមិនដូច្នោះទេ រណៈសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានឹងមិនទទួលខុសត្រូវចំពោះឧបទ្ទវហេតុណាមួយដែលកើតឡើងនោះឡើយ។

៧. តាំងនាមឲ្យប្រជាជាតិ និងប្រជាជនកម្ពុជា រណៈសិរ្សរួបរួមជាតិកម្ពុជាដែលមានសម្តេចប្រធានរដ្ឋនរោត្តមសីហនុជាព្រះប្រធាន រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលមានសម្តេចប៉ែន នុតជានាយករដ្ឋមន្ត្រី និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា ជាថ្មីម្តងទៀត សមាជជាតិសូមសំដែងនូវកត្តញ្ញូតាធម៌ និងការដឹងគុណដ៏ជ្រាលជ្រៅចំពោះប្រជាជននៃបណ្តាប្រទេសជាបងប្អូនជិតឆ្ងាយទាំងអស់ និងចំពោះប្រជាជនអាមេរិកដែលស្នេហាសន្តិភាព យុវជន និងអ្នកមុខអ្នកការទាំងអស់ចំពោះការគាំទ្រ និងការជួយឧបត្ថមដល់ប្រជាជនកម្ពុជានៅក្នុងការតស៊ូដ៏យុត្តិធម៌ និង ការរំដោះប្រជាជនរបស់ពួកគេ។ សមាជជាតិសូមអំពាវនាវដល់ប្រជាជន និងប្រទេសជាមិត្តភក្តិទាំងអស់ទាំងនៅទីជិត ទាំងនៅទីឆ្ងាយ រួមទាំងប្រជាជនអាមេរិក យុវជន និងអ្នកមុខអ្នកការទាំងអស់ដែលស្រឡាញ់សន្តិភាព និងយុត្តិធម៌ សូមបន្តជួយគាំទ្រ និងឧបត្ថមចំពោះការតស៊ូដ៏យុត្តិធម៌របស់ប្រជាជាតិ និងប្រជាជនកម្ពុជា ជាពិសេស ដើម្បីពិនិត្យមើលឧបាយកលអន្តរាគមន៍ និងឈ្លានពាន

ទាំងអស់ ព្រមទាំងសកម្មភាពទាំងអស់របស់រដ្ឋបាល Ford-Kissinger ដើម្បីអាចឲ្យប្រជាជនកម្ពុជាដោះស្រាយបញ្ហារបស់ខ្លួនដោយមិនមានការធ្វើអន្តរាគមន៍ពីបរទេសណាមួយ។

៨. តាំងនាមឲ្យប្រជាជាតិ និងប្រជាជនកម្ពុជា រណៈសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សមាជជាតិសូមអំពាវនាវដល់ប្រជាជនកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជាទាំង ៣ប្រភេទ សូមបន្តពង្រឹងស្មារតីវាយប្រយុទ្ធ និងបន្តវាយប្រហារខ្លាំងឲ្យបានខ្លាំងក្លា និងច្រើនឡើងថែមទៀត ទាំងនៅខ្សែត្រៀមខាងមុខ និងខ្សែត្រៀមខាងក្រោយ ដើម្បីសម្រេចបាននូវភារៈកិច្ចរំដោះប្រជាជាតិ និងប្រជាជនយើងទាំងស្រុង និងជាអចិន្ត្រៃយ៍។

តំបន់រំដោះនៃប្រទេសកម្ពុជា ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ១៩៧៥

សម្រាប់សម័យប្រជុំលើកទី ២នៃសមាជជាតិរបស់រណៈសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា

ប្រធាននៃសមាជជាតិ

[ហត្ថលេខា] ខៀវ សំផន